**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៖ ៦៩ អនក្រ.បក

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការ**

**ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីបង្ក្រាបសកម្មភាពឈូសឆាយដីព្រៃកោងកាង ការឈូសឆាយ**

**ចាក់ដីបំពេញលើដីចំណីឆ្នេរសមុទ្រ**

*****

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ-បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សំរេច**

**ប្រការ១:** បង្កើតគណៈកម្មការត្រួតពិនិត្យ និងវាយតំលៃ ដើម្បីបង្ក្រាបសកម្មភាពទន្ទ្រានដីព្រៃកោងកាង ការឈូសឆាយ ចាក់ដីបំពេញលើដីចំណីឆ្នេរសមុទ្រ ដែលបង្កការប៉ះពាល់យ៉ាងខ្លាំងលើស្ថានភាពរូបសាស្ត្រ អេកូឡូស៊ី តំបន់ទេសភាព ការបំផ្លាញបរិស្ថានតំបន់ឆ្នេរសមុទ្រ ។

**ប្រការ២:** គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម:

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២-រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៣-រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ | សមាជិក |
| ៤- រដ្ឋលេខាធិការ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៦-អភិបាលក្រុងព្រះសីហនុ | សមាជិក |
| ៧-អភិបាលក្រុងកែប | សមាជិក |
| ៨-អភិបាលខេត្តកំពត | សមាជិក |
| ៩-អភិបាលខេត្តកោះកុង | សមាជិក |
| ១០-អគ្គនាយកបច្ចេកទេស ក្រសួងបរិស្ថាន | លេខាធិការ |
| ១១-ប្រធានសំរបសំរួលតំបន់ឆ្នេរសមុទ្រ ក្រសួងបរិស្ថាន | លេខាប្រចាំការ |

**ប្រការ៣:** គណៈកម្មការនេះមានតួនាទី និងភារៈកិច្ចដូចខាងក្រោម:

- ត្រួតពិនិត្យ និងវាយតំលៃរាល់សកម្មភាពទន្ទ្រានដីព្រៃកោងកាង ការឈូសឆាយ និងចាក់ដីបំពេញលើដីចំណីឆ្នេរសមុទ្រ ។
- បញ្ឈប់រាល់សកម្មភាពទាំងឡាយណាដែលបានរំលោភយកដីព្រៃ និងដីចំណីឆ្នេរ មានការធ្វើសំណង់គ្រប់ប្រភេទ - ការចាក់ខឿនបេតុង - បោះបង្គោល ឬរៀបដុំថ្មជាដុំៗធ្វើជាខឿនដើម្បីចាក់ដី -ការធ្វើរបងការលប់បំពេញដី ទោះជាបូមដីចាក់ក្ដី ឬជីកដឹកដីយកមកចាក់ក្ដី លើតំបន់ព្រៃកោងកាងធ្វើជាកម្មសិទ្ធិ។ល។
- ត្រូវដកហូតមកវិញរាល់ដីព្រៃ និងដីចំណីឆ្នេរជាប់មាត់សមុទ្រ ដែលត្រូវបានរំលោភដោយល្មើសច្បាប់ទុកជាសម្បត្តិរដ្ឋ ។
- ជនល្មើសត្រូវដាំព្រៃកោងកាងឱ្យដូចលក្ខណៈដើមវិញ នៅតំបន់ដែលបានកាប់ព្រៃកោងកាង និងតំបន់ដែលបានចាក់ដីលប់នោះ ហើយតំបន់នោះនឹងត្រូវដកហូតទុកជាសម្បត្តិរដ្ឋ ។

**ប្រការ ៤:** គណៈកម្មការនេះមានសិទ្ធិសុំកំលាំងអន្តរាគមន៍ពីស្ថាប័នមានសមត្ថកិច្ច ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

**ប្រការ៥:** គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មការជាជំនួយសំរាប់អនុវត្តការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសតាមបញ្ជារបស់គណៈកម្មការ ។

**ប្រការ ៦:** គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន និងមានលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិសំរបសំរួលតំបន់ឆ្នេរ ជាជំនួយការកិច្ចការរដ្ឋបាល ។

**ប្រការ៧:** គណៈកម្មការនេះត្រូវរាយការណ៍អំពីការអនុវត្តរបស់ខ្លួនជូនរាជរដ្ឋាភិបាលឱ្យបានទៀងទាត់ ។

**ប្រការ៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាជ្ញាធរក្រុងកែប អាជ្ញាធរក្រុងព្រះសីហនុ អាជ្ញាធរខេត្តកំពត អាជ្ញាធរខេត្តកោះកុង និងសហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ